00743685

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

E117/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 23 / 09 / 2011
ម៉ោង (Time/Heure) : 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**អង្គជំនុំជម្រះសាលាដំបូង**

**សាធារណៈ / Public**

ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១

**ជូនចំពោះ:** **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង**
**លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះតុលាការកំពូល**
**ភាគីទាំងអស់នៃសំណុំរឿង ០០២ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើ"សារណាស្តីពីសំណើសុំធ្វើការពិចារណាឡើងវិញ និងកែតម្រូវអនុស្សរណ:** E62/3/10/4"(**ឯកសារ** E62/3/10/4/1) **និងសំណើសុំ** E117

យោងតាមសារណា E62/3/10/4/1 ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១ ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញនូវសេចក្តីសម្រេចដោយសម្លេងភាគច្រើនរបស់ខ្លួន ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ (ឯកសារ E62/3/10/4) ដែលបានរឹតត្បិតការចែកចាយរបាយការណ៍អ្នកជំនាញស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នួន ជា (ដែលជាប្រភេទឯកសារសម្ងាត់បំផុត) ដោយអនុញ្ញាតឱ្យតែសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ដែលសហមេធាវីនាំមុខបានចាត់តាំងឱ្យជួយដល់ខ្លួនលើបញ្ហានេះប៉ុណ្ណោះ ទើបមានសិទ្ធិពិនិត្យមើលរបាយការណ៍ទាំងនេះ ដោយអនុលោមតាមវិធាន ១២ *ស្ទួនពីរ*(៦)។

សេចក្តីសម្រេចនេះបានធ្វើឡើងបន្ទាប់ពីក្រុមមេធាវីការពារក្តីជនជាប់ចោទទាំង ២ រូបបានស្នើសុំដាក់កំហិតការពិនិត្យរបាយការណ៍ទាំងនេះ និងបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងយល់អំពីសារៈសំខាន់នៃការថ្លឹងថ្លែងរវាង "សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការរក្សាភាពសម្ងាត់ឯកជនអំពីព័ត៌មានខាងផ្នែកវេជ្ជសាស្ត្រ ជាមួយនឹងសិទ្ធិជាមូលដ្ឋានរបស់សាធារណជនក្នុងការដឹងអំពីព័ត៌មានទាំងនេះ នៅពេលដែលសំណើសុំរបស់ខ្លួនស្តីពីបញ្ហាសម្បទាក្នុងការចូលរួមសវនាការកំពុងស្ថិតក្នុងការពិចារណារបស់អង្គជំនុំជម្រះ" (ឯកសារលេខ E62/3/10)។ ទោះជាយ៉ាងណាក្តី ដីកាកំណត់កាលបរិច្ឆេទសវនាការរបស់អង្គជំនុំជម្រះដែលបានចេញនៅមុនពេលមានសវនាការលើបញ្ហាសម្បទារបស់ជនជាប់ចោទ(ឯកសារលេខ E110)

បានបញ្ជាក់ថាសវនាការនេះនឹងធ្វើជាសាធារណៈឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង ធីរិទ្ធ បានដាក់ការជំទាស់ជាថ្មីម្តងទៀតចំពោះសំណើសុំរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ។ មេធាវីការពារក្តី អៀង ធីរិទ្ធ ស្នើអង្គជំនុំជម្រះរក្សាចំណាត់ថ្នាក់ឯកសារដដែល និងបន្តកំរិតសិទ្ធិក្នុងការចូលមើលឯកសារសម្ងាត់បំផុតនានាដែលត្រូវបានយោងនៅក្នុងការដេញដោលនាពេលសវនាការជាសាធា-រណៈស្តីពីសម្បទារបស់ជនជាប់ចោទ (ឯកសារលេខ E117/1)។

នៅក្នុងសំណើដែលមានលេខ E62/3/10/4/1 សហមេធាវីនាំមុខបានស្នើសុំឱ្យអង្គជំនុំជម្រះ កែតម្រូវសេចក្តីសម្រេចលេខ E62/3/10 និង E62/3/10/4 និងអនុញ្ញាតឱ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ចំនួន ៣៧ រូប អាចពិនិត្យមើលរបាយការណ៍វេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធផ្សេងទៀតនៅក្នុងសំណុំរឿង។ សហមេធាវីនាំមុខក៏បានស្នើសុំការបញ្ជាក់បំភ្លឺអំពីប្រភេទគតិយុត្តិនៃឯកសារលេខ E62/3/10/4 ផងដែរ។

កាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១១ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខ (ឯកសារលេខ E62/3/10/5) ជំទាស់នឹងសេចក្តីសម្រេចលេខ E62/3/10/4 ទៅអង្គជំនុំជម្រះតុលាការកំពូលដោយ អនុលោមតាមវិធាន ១០៥(២) និង វិធាន ១០៥(៣), វិធាន ១០៦ និង វិធាន ១០៧ (៤) នៃវិធានផ្ទៃក្នុង បើទោះបីមកទល់នឹងពេលនេះ អង្គជំនុំជម្រះសាលាដំបូងពុំទាន់បានសម្រេចលើសំណើសុំរបស់សហមេធាវីនាំមុខលេខ E62/3/10/4/1 ក្តី។ នៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកលើមូលដ្ឋាននៃភាពអាចទទួលយកបាននៃបណ្តឹងនេះ (ឯកសារលេខ E62/3/ 10/5/1)។

នៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១១ សហមេធាវីនាំមុខបានដាក់សំណើមួយទៀត (ឯកសារលេខ E117) សុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់ថ្នាក់ជាឯកសារសម្ងាត់ ចំពោះរាល់ឯកសារទាំងអស់ដែលពាក់ព័ន្ធទៅនឹងបញ្ហាសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ដែលឯកសារទាំងនេះត្រូវបានដាក់ និងពិភាក្សាជាសាធារណៈនៅក្នុងសវនាការស្តីពីសម្បទាក្នុងការចូលរួមសវនាការកាលពីថ្ងៃទី ២៩ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១។

នៅក្នុងការសម្រេចលើសំណើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញនេះ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ឃើញថាសវនាការរយៈពេល ៣ ថ្ងៃពាក់ព័ន្ធនឹងកាយសម្បទារបស់ជនជាប់ចោទ នួន ជា និង អៀង

ធីរិទ្ធ ត្រូវបានធ្វើជាសាធារណៈ។ ដោយហេតុថារបាយការណ៍អ្នកជំនាញដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំពិនិត្យដោយគ្មានការរឹតត្បិតត្រូវបានលើកមកពិភាក្សាជាទូទៅក្នុងអំឡុងពេលសវនាការនេះ ហើយអង្គជំនុំជម្រះក៏បានសម្រេចដោយផ្ទាល់មាត់ ឱ្យចាត់ថ្នាក់ជាឯកសារសាធារណៈ នូវរាល់ឯកសារទាំងអស់ដែលធ្លាប់ជាឯកសារសម្ងាត់បំផុត រួមទាំងរបាយការណ៍របស់អ្នកជំនាញ ២ ផងដែរ។ ការសម្រេចនេះមានខ្លឹមសារដូចខាងក្រោម៖

> អង្គជំនុំជម្រះកត់សម្គាល់ថា ខ្លួនបានចាត់ថ្នាក់ជាដំបូងនូវឯកសារមួយចំនួនពាក់ព័ន្ធនឹងស្ថានភាពវេជ្ជសាស្ត្ររបស់ជនជាប់ចោទជាឯកសារសម្ងាត់បំផុតជាបណ្ដោះអាសន្ន។ អង្គជំនុំជម្រះរំឮកថាតាមមាត្រា៩ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ថ្នាក់ឯកសារ ការចាត់ថ្នាក់ឯកសារឡើងវិញអាចធ្វើបានគ្រប់ពេល។ ក្នុងករណីនេះ អង្គជំនុំជម្រះត្រូវពិភាក្សាជាមួយនឹងភាគីដែលពាក់ព័ន្ធ។ អង្គជំនុំជម្រះរំឮកបន្ថែមថាសេចក្ដីសម្រេចរបស់ខ្លួនកាលពីម្សិលមិញថា ការពិភាក្សាអំពីបញ្ហាវេជ្ជសាស្ត្រ និងសមត្ថភាពខាងសម្បទាត្រូវធ្វើជាសាធារណៈដើម្បីពន្លឿនកិច្ចនីតិវិធី។ ភាគីណាដែលមានបំណងដាក់ឯកសារដែលដំបូងត្រូវបានចាត់ថ្នាក់ជាសម្ងាត់ ឬសម្ងាត់បំផុតនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសវនាការជាសាធារណៈ អាចធ្វើបានដោយមិនចាំបាច់សុំជាផ្លូវការទេ។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងមិនជំទាស់ទេនោះ ឯកសារនោះត្រូវចាត់ទុកថាត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ ជាឯកសារសាធារណៈ (ប្រតិចារឹក, ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១, កថាខណ្ឌ ១-២)។

អង្គជំនុំជម្រះកត់សម្គាល់សំណើចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ដែលបានស្នើសុំឱ្យរក្សាចំណាត់ថ្នាក់ឯកសារខាងលើដដែល ដោយជំទាស់ទៅនឹងការចាត់ថ្នាក់ឯកសារទាំងនេះឡើងវិញជាសាធារណៈ ពីព្រោះថាផ្នែកជាច្រើននៃឯកសារទាំងនេះត្រូវបានលើកយកមកដេញដោលជាសាធារណៈរួចហើយ (ឯកសារលេខ E117/1)។ អង្គជំនុំជម្រះយល់ពីគោលបំណងរបស់មេធាវីការពារក្ដី អៀង ធីរិទ្ធ ដែលកន្លងមកមិនជំទាស់ចំពោះការយករបាយការណ៍មកដេញដោលជាសាធារណៈត្រង់ផ្នែកនានាដែលអាចយកមកដេញដោលជាសាធារណៈបាន ប៉ុន្តែមេធាវីជំទាស់ចំពោះការធ្វើចំណាត់ថ្នាក់ជាសាធារណៈលើរបាយការណ៍នេះទាំងមូល។ ដោយហេតុថា របាយការណ៍នេះត្រូវបានដាក់ដេញដោលស្ទើរតែទាំងស្រុងក្នុងសវនាការជាសាធាណៈ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចផ្លាស់ប្ដូរចំណាត់ថ្នាក់ឯកសារទាំងនោះមកជាឯកសារសាធារណៈវិញ។ ដោយសារតែមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលពិនិត្យមើលឯកសារទាំងនេះបានហើយនោះ ដូច្នេះសំណើសុំលេខ E62/3/10/4/1 គឺពុំមែនជាសំណើចាំបាច់ទៀតឡើយ។

ពាក់ព័ន្ធទៅនឹងសំណើ E117 អង្គជំនុំជម្រះកត់សម្គាល់ថា បញ្ជីឯកសារដែលសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញនោះ គឺហួសពីឯកសារដែលត្រូវបានដាក់ និង

បានដេញដោលនៅក្នុងសវនាការស្តីពីសម្បទាកន្លងទៅ។ អង្គជំនុំជម្រះយល់ថា មិនមានមូលដ្ឋានដែលអង្គជំនុំជម្រះត្រូវធ្វើចំណាត់ថ្នាក់ឯកសារទាំងនោះឡើងវិញឡើយ។

អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថាសេចក្តីសម្រេចលេខ E62/3/10 និង E62/3/10/4 ដែលមានហត្ថលេខារបស់ប្រធានអង្គជំនុំជម្រះ និងដែលបានជូនដំណឹងដល់ភាគីតាមនីតិវិធីដែលបានអនុវត្តនោះ គឺជាសេចក្តីសម្រេចផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូង និងបើកផ្លូវប្តឹងសាទុក្ខ (ក្នុងករណីភាគីមានសិទ្ធិប្តឹងសាទុក្ខ)។ អនុលោមតាមឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចក្នុងទម្រង់ជាអនុស្សរណៈ នៅពេលកម្មវត្ថុមានការពាក់ព័ន្ធច្រើនទៅនឹងការរៀបចំសវនាការដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថានេះជាការដាក់សំណើលើកទី២លើបញ្ហានេះពីសំណាក់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលអង្គជំនុំជម្រះយល់ថាពុំមានភាពចាំបាច់ឡើយ។ កាលពីអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះធ្លាប់បានរំឭកដល់ភាគីថា មិនគួរដាក់នូវសំណើដែលមានភាពច្រំដែល និងវែងអន្លាយ ពាក់ព័ន្ធនឹងបញ្ហាដែលអង្គជំនុំជម្រះធ្លាប់បានសម្រេច រួចមកហើយនោះទេ គឺដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា សំណើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញពុំមានចែងក្នុងក្របខណ្ឌគតិយុត្ត អ.វ.ត.ក ឡើយ ហើយភាគីអាចប្តឹងសាទុក្ខបានក្នុងករណីដែលខ្លួនមានសិទ្ធិធ្វើដូច្នេះប៉ុណ្ណោះ។

នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំ E62/3/10/4/1 និង E117។